# GC ការពារក្រេឌីត



## តើអ្វីទៅជា GC ការពារក្រេឌីត?

GC ការពារក្រេឌីត គឺជាគម្រោងធានារ៉ាប់រងដែលផ្តល់ការការពារលើឥណទានរបស់លោកអ្នក ក្នុងករណីមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ គម្រោងនេះធានាបានថាគ្រួសាររបស់លោកអ្នកនឹងមិនមានទុក្ខកង្វល់ក្នុងការសងបំណុលឡើយ ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើង។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | ចាប់ពី 18 ដល់ 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1 - 30ឆ្នាំ |
| វិធីសាស្ត្របង់បុព្វលាភ | បង់ម្តងផ្តាច់ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $1,000ឡើង |
| ប្រភេទនៃទឹកប្រាក់ត្រូវបានធានា | ប្រភេទថេរ ឬប្រភេទថយចុះ |

- ប្រភេទថេរ មានន័យថាទឹកប្រាក់ត្រូវបានធានានៅរក្សាចំនួនថេរដដែលក្នុងអំឡុងពេលធានារ៉ាប់រង។

- ប្រភេទថយចុះ សំដៅទៅលើទឹកប្រាក់ត្រូវបានធានាដែលនឹងត្រូវថយចុះជារៀងរាល់ឆ្នាំនៅថ្ងៃខួបនៃបណ្ណសន្យារ៉ាប់រង។

## អត្ថប្រយោជន៍ធានារ៉ាប់រង

**សំណងមរណភាព**
100% នៃទឹកប្រាក់ត្រូវបានធានា

**សំណងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**
100% នៃទឹកប្រាក់ត្រូវបានធានា

## ករណីមិនធានា

**១. មរណភាព**

(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្ដើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង។
(២) ការប្រព្រឹត្តិ ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លោចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

(១) សង្គ្រាម សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាព ប្រឆាំងនឹងរដ្ឋាភិបាលនិងអំពើភេរវកម្ម។
(២) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។
(៣) ស្ថានភាពដែលមានពីមុនស្រាប់មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព។
(៤) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ខ្លះៗប៉ុណ្ណោះ។ សម្រាប់ករណីមិនធានាលម្អិតទាំងស្រុង សូមពិនិត្យមើល ខ និងលក្ខខណ្ឌធានារ៉ាប់រង។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ